គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

ខុមហ្វ្រែល **COMFREL**

គណៈកម្មាធិការនាយក
**BOARD OF DIRECTORS**

លោក ធន សារាយ
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក សុក សំអឿន
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក យឹម ប៉ូ
**Mr. YIM Po** អគ្គហេរញ្ញិក
និង នាយក **CCPCR**

កញ្ញា ស៊ុន ចាន់សែន
**Miss. SUN Chansen**
ប្រធាន **KYA**

លោក មុំ សារិន
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី ពឹង យក់ហៀប
**Ms. PEUNG Yok Hiep**

លោកស្រី ទីវ សារាយេត
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា សយ សារា វឌ្ឍនី
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក គឹម សុវណ្ណ
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក អាង ច័ន្ទឫទ្ធិ
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក យង់ គិមអេង
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក ភួង សិទ្ធិ
**Mr. PHUONG Sith**

លោក សឺន សែត
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ០៤/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច
# ពិសេសទូរទស្សន៍ជាតិកម្ពុជា (ទទក)

*ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩*

គណៈកម្មាធិការខុមហ្វ្រែលសង្កេតឃើញថា ក្នុងអំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៤ និងក្រោយពេលបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចបានផ្តោតខ្លាំងលើគណបក្សនយោបាយសំខាន់ៗមួយចំនួនដែលមានអាសនៈក្នុងសភា និងក្រុមប្រឹក្សាឃុំ-សង្កាត់ ខណៈដែលគណបក្សនយោបាយផ្សេងទៀតភាគច្រើនត្រូវបានផ្សព្វផ្សាយតែក្នុងអំឡុងពេលឃោសនាបោះឆ្នោត ក្នុងកម្មវិធីផ្សព្វផ្សាយរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅក្នុងប្រព័ន្ធផ្សព្វផ្សាយជាតិ។ ទោះយ៉ាងណា គណបក្សប្រជាជនកម្ពុជាទទួលបានការផ្សព្វផ្សាយច្រើនជាងគេ។

ក្នុងអំឡុងពេលបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចរដ្ឋទាំង ៣ (ទូរទស្សន៍ជាតិកម្ពុជា-ទទក វិទ្យុជាតិ FM 96 MHz និង AM 918 KHz) បានផ្សព្វផ្សាយលំអៀងយ៉ាងខ្លាំងទៅរកគណបក្សប្រជាជនកម្ពុជា រួមទាំងការផលិតកម្មវិធីផ្សព្វផ្សាយ ឃោសនា សរសើរដល់គណបក្ស ប្រជាជនកម្ពុជា និងរិះគន់បង្អាប់ដល់គណបក្សនយោបាយដទៃផងដែរ។

ដោយឡែក ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ FM 102 MHz វិទ្យុ FM 105 MHz វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) វិទ្យុអាស៊ីសេរី (RFA) វិទ្យុបារាំងអន្តរជាតិ (RFI) បានផ្សព្វផ្សាយពីគណបក្សទាំងកាន់អំណាច និងមិនកាន់អំណាច តែភាគច្រើនផ្តោតទៅលើគណបក្ស សមរង្ស៊ី ប្រជាជនកម្ពុជា សិទ្ធិមនុស្ស ហ៊្វុនស៊ិនប៉ិច និងនរោត្តមរណឫទ្ធិ ក្នុងរយៈពេលច្រើនប្រហាក់ប្រហែលគ្នា ហើយខ្លឹមសារនៃការផ្សព្វផ្សាយមានលក្ខណៈចម្រុះ វិជ្ជមាន អវិជ្ជមាន និង អព្យាក្រឹត។

ក្រោយពីការបោះឆ្នោត ខុមហ្វ្រែលនៅបន្តអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ ជាពិសេស ទទក។ បើទោះបីមានការធ្លាក់ចុះនៃការផ្សាយខាងនយោបាយ និងការបោះឆ្នោតក៏ដោយ ប៉ុន្តែព័ត៌មានអំពីសកម្មភាពរបស់ រាជរដ្ឋាភិបាលទាំងថ្នាក់ជាតិ ដូចជាការចូលរួមកិច្ចប្រជុំនានា ការជួបជាមួយគណៈប្រតិភូ

ឬតំណាងស្ថាប័នអន្តរជាតិនានា និងការចុះមូលដ្ឋានដោយផ្តោតទៅលើសកម្មភាពអភិវឌ្ឍន៍ ការចែកអំណោយដល់ប្រជាពលរដ្ឋនៅដដែល។

ការផ្សព្វផ្សាយពីគណបក្សនយោបាយ ទូរទស្សន៍ទាំងអស់ ជាពិសេសបណ្តាញទូរទស្សន៍កម្ពុជា ស៊ីធីអិន បន្តផ្តល់ឱកាសច្រើនដល់គណបក្សប្រជាជនកម្ពុជាផ្សព្វផ្សាយព័ត៌មានទាក់ទិនដល់ប្រយោជន៍សម្រាប់គណបក្សនេះ និងតិះទៀនគណបក្សផ្សេងៗទៀត ពិសេសគណបក្សប្រឆាំង។ ឧទាហរណ៍ ទាំងមុន ក្នុងអំឡុងពេល និងក្រោយពេលឃោសនាបោះឆ្នោត ដូចជាបណ្តាញទូរទស្សន៍កម្ពុជាស៊ីធីអិន (CTN) បានផលិតកម្មវិធី **"ទេពកោសល្យ និងស្នាដៃ"** ដែលភាគច្រើនផ្សព្វផ្សាយ ពីសមិទ្ធិផលរបស់គណបក្សប្រជាជនកម្ពុជា និងពេលខ្លះរិះគន់ដល់គណបក្សប្រឆាំង។

នៅក្នុងកម្មវិធីទូរទស្សន៍ ស៊ីធីអិន ផ្សាយថ្ងៃទី ១២ មីនា ឆ្នាំ ២០០៩ ពិធីករបានធ្វើការរិះគន់គណបក្សហ្វ៊ុនស៊ិនប៉ិច និងនរោត្តមរណឫទ្ធិ ហើយថា សមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិចគួរបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។

ការសង្កេតរកឃើញថា ការផ្សព្វផ្សាយព័ត៌មាននយោបាយរបស់ទូរទស្សន៍ជាតិកម្ពុជា (ទទក) ក្នុងកំឡុងពេលពីខែ តុលា ២០០៨ ដល់ មីនា ២០០៩[១] នេះ តួអង្គនយោបាយ[២] រាជរដ្ឋាភិបាលត្រូវបានបង្ហាញរហូតដល់ ៦៨% (ស្មើនឹង ៤.២១២ ដង) នៃការផ្សព្វផ្សាយពីតួអង្គនយោបាយទាំងអស់ចំនួន ៦.១៦៤ ដង។ ក្នុងនោះការផ្សព្វផ្សាយ បែបវិជ្ជមានលើកសរសើរដល់រាជរដ្ឋាភិបាលមានចំនួន ១១៣ លើក ខណៈដែលការផ្សព្វផ្សាយបែបអវិជ្ជមាន មិនត្រូវបានបង្ហាញ។ ការផ្សព្វផ្សាយពីរាជរដ្ឋាភិបាល ភាគច្រើនលើសលប់ត្រូវបានផ្សព្វផ្សាយក្នុងកម្មវិធី ព័ត៌មានក្នុងប្រទេសដែលផ្សព្វផ្សាយពីសកម្មភាពរបស់សមាជិករាជរដ្ឋាភិបាល និងព័ត៌មានសបាគមន៍ជាតិ ដែលភាគច្រើនផ្សព្វផ្សាយពីការចុះមូលដ្ឋាន ការចុះសួរសុខទុក្ខ ការចែកអំណោយ...ដល់ប្រជាពលរដ្ឋពីសំណាក់ សមាជិករាជរដ្ឋាភិបាល។

ដោយឡែកនាយករដ្ឋមន្ត្រីតែឯង ត្រូវបានផ្សព្វផ្សាយច្រើនលំដាប់ទី ២ គឺ ២០% (ស្មើនឹង **១,២៤៩ ដង**) ដែលក្នុងនោះព័ត៌មានវិជ្ជមានចំនួន **៣១០ ដង** ខណៈការផ្សព្វផ្សាយបែបអវិជ្ជមានមិនត្រូវបានឃើញ។ ក្រៅពីការបង្ហាញក្នុងកម្មវិធីព័ត៌មាន ជារឿយៗសកម្មភាពចុះមូលដ្ឋាន និងសុន្ទរកថារបស់នាយករដ្ឋមន្ត្រី ត្រូវបានចាក់ផ្សាយទាំងស្រុង។

រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបានបង្ហាញ និងឮ ១០% (ស្មើនឹង **៥៩៨ ដង**)។ ការផ្សព្វផ្សាយពីរដ្ឋសភា និងព្រឹទ្ធសភា ភាគច្រើនទាក់ទងនឹងសកម្មភាពប្រជុំរបស់សមាជិកសភា ជាមួយគណៈប្រតិភូបរទេស និងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រជាដើម។

ទោះបីយ៉ាងណា ប្រព័ន្ធផ្សព្វផ្សាយរដ្ឋទាំងនេះ បានគោរពទៅតាមគោលការណ៍ណែនាំរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត ដោយមិនឃើញមានការ

[១] ការផ្សាយពីម៉ោង ១៨:០០ ដល់ ម៉ោង ២៣:០០ រៀងរាល់ថ្ងៃ តែមិនរាប់បញ្ចូលកម្មវិធី ព័ត៌មានសមធមិទេ។

[២] តួអង្គនយោបាយរួមមានៈ នាយករដ្ឋមន្ត្រី សមាជិករាជរដ្ឋាភិបាល/មន្ត្រីរាជការ ស្ថាប័ន/សមាជិករដ្ឋសភា ព្រឹទ្ធសភា និងគណបក្សនយោបាយមានអាសនៈ ក្នុងរដ្ឋសភា។

ផ្សាយលំអៀង និងផ្សាយពីកម្មវិធីគាំទ្រគណបក្សប្រជាជនកម្ពុជាទេ ឬប្រឆាំងគណបក្សផ្សេងទៀត ប៉ុន្តែក្រោយពេលបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ពិសេស ទទក មិនបានគោរពគោលការណ៍មិនលំអៀងឬធ្វើឱ្យមានតុល្យភាពព័ត៌មានទេ។

គណបក្សនយោបាយទាំង ៥ ដែលមានអាសនៈក្នុងរដ្ឋសភាត្រូវបានបង្ហាញ ឬឮតែ ២% (ស្មើនឹង ១០៩ ដង) ប៉ុណ្ណោះ។ ការផ្សព្វផ្សាយពីគណបក្សនយោបាយ មានភាពលំអៀងយ៉ាងខ្លាំងទៅរកគណបក្ស ប្រជាជនកម្ពុជាទាំងពេលវេលា និងខ្លឹមសារវិជ្ជមាន។

៨១% (ស្មើនឹង ៨៨ ដង) នៃការផ្សាយពីគណបក្សនយោបាយគឺបង្ហាញ និងលើកឡើងពីគណបក្ស ប្រជាជនកម្ពុជា ដែលក្នុងនោះការផ្សព្វផ្សាយបែបវិជ្ជមានចំនួន ១២លើក និងព័ត៌មានដែលមានលក្ខណៈ អវិជ្ជមានតែមួយលើកប៉ុណ្ណោះ។ ទទក ក៏បានផ្តល់ឱកាសដល់តែមន្ត្រីគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះក្នុងការការពារខ្លួន ការឃោសនាបោះឆ្នោត និងការរិះគន់ដល់គណបក្សដទៃមិនចំឈ្មោះ។

គ្មានឧទាហរណ៍ណាមួយដែល ទទក បានចាក់ផ្សាយការសម្ភាសន៍ ឬសុន្ទរកថារបស់មេដឹកនាំគណបក្សប្រឆាំង (ក្រៅតែពីមតិនៅក្នុងការចាក់ផ្សាយនៃការពិភាក្សានៅក្នុងសភា) ប៉ុន្តែការផ្សាយដ៏ច្រើនលើសលប់នូវសន្ទរកថារបស់អ្នកដឹកនាំគណបក្សប្រជាជនកម្ពុជា ដូចជានៅថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០០៩ **ទទក** បានចាក់ផ្សាយសុន្ទកថារបស់សម្តេច **ជា ស៊ីម** ប្រធាន គណបក្សប្រជាជនកម្ពុជាអះអាងបញ្ជាក់អំពីសម័្ពន្ធភាពផ្ទៃក្នុងរបស់គណបក្សប្រជាជនកម្ពុជាថា **គ្មានទម្លាប់ដណ្តើម អំណាចគ្នាទេ** និងគោលជំហរនៅតែ**គាំទ្របេក្ខភាពនាយករដ្ឋមន្ត្រី សម្តេច ហ៊ុន សែន គ្រប់អាណត្តិផងដែរ** ដែលនេះជាការ ឆ្លើយតបទៅនឹងពាក្យចចាមអារាមពីការរង្គោះរង្គើខ្លះៗនៅក្នុងជួរ គណបក្សកាន់អំណាច។ ដោយឡែកនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៩ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** អនុប្រធានគណបក្សប្រជាជនកម្ពុជាបានរិះគន់គោលនយោបាយរបស់គណបក្សប្រឆាំង ដោយមិនបញ្ចេញឈ្មោះ និងបានឃោសនាពីសមិទ្ធផលរបស់ខ្លួន និងផ្សព្វផ្សាយថា *"ប្រសិនបើ គណបក្សប្រជាជនកម្ពុជាបន្តកាន់អំណាច ហើយ ហ៊ុន សែន នៅជានាយករដ្ឋមន្ត្រី គោលនយោបាយមិនយកពន្ធដីនៅតែ បន្ត"* ហើយត្រូវបានចាក់ផ្សាយដោយ ទទក។

ចំណែកការផ្សព្វផ្សាយពីគណបក្សនយោបាយ ៤ ផ្សេងទៀតរួមគ្នាមានតែ ១៩% (ស្មើនឹង ២១ លើកប៉ុណ្ណោះ)។ ហើយគណបក្សនយោបាយទាំងនេះ ភាគច្រើនត្រូវបានឮ នៅក្នុងសេចក្តីថ្លែងសុន្ទរកថារបស់នាយករដ្ឋមន្ត្រីសម្តេច ហ៊ុន សែន។

**ព័ត៌មានសមធម៌ប្រចាំសប្តាហ៍ បានផ្តល់ឱកាសច្រើនដល់ប្រជាពលរដ្ឋបញ្ចេញមតិទៅលើប្រធានបទផ្សេងៗរបស់កម្មវិធី។** ការផលិតកម្មវិធីក៏គោរពទៅតាមបែបវិជ្ជាជីវៈផងដែរ ដោយផ្តល់ឱកាសដល់គ្រប់ភាគីពាក់ព័ន្ធមិនថាមាននិន្នាការនយោបាយបែបណាទេ ធ្វើការបកស្រាយទៅលើប្រធានបទដែលបានលើកឡើង។ ជាមួយគ្នានេះ កម្មវិធីនេះភាគច្រើនបានផ្តល់ឱកាសដល់ប្រធានអង្គការមិនមែនរដ្ឋាភិបាល ជាវាគ្មិនទៅលើប្រធានបទផ្សេងៗដែលកំពុងពិភាក្សា។

តែកម្មវិធីនេះ មិនបានផ្តោតទៅលើតួអង្គនយោបាយ ជាពិសេសគណបក្សនយោបាយនោះទេ។ នៅក្នុងរយៈពេលអង្កេតនេះ កម្មវិធីសមធម៌បានផ្សាយពីតួអង្គនយោបាយៗ (រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រី សភា គណបក្សនយោបាយ) រហូតដល់ **១១៣** លើក ដែលក្នុងចំនួននោះការផ្សព្វផ្សាយពី គណបក្សនយោបាយ គឺមានចំនួនតិចតួច

ត្រឹមតែ **៩** លើក ខណៈដែលតួអង្គតំណាងឱ្យរាជរដ្ឋាភិបាល ត្រូវបានផ្សព្វផ្សាយរហូតដល់ **១០១** លើក និងតួអង្គផ្សេងៗ ចំនួន **៧** លើក។

ខុមហ្វ្រែល បាននិងកំពុងបន្តអង្កេតប្រព័ន្ធផ្សព្វផ្សាយ ជាពិសេស ទូរទស្សន៍ជាតិកម្ពុជា (ទទក) ហើយខុមហ្វ្រែល នឹងចេញរបាយការណ៍ស្តីពីការអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយនេះជារៀងរាល់ ៦ខែ ម្តង។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:*

- លោក ច័ន្ទ ដារិទ្ធ អ្នកសម្របសម្រួលផ្នែកព័ត៌មាន ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក សុខ ពិទូរ្យ អ្នកសម្របសម្រួលស្តីទីផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦